ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែតុលា និងទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០១៣

នៅក្នុងខែតុលានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានបំពេញការងារយ៉ាងសកម្ម លើការដ្ឋានជាច្រើនដោយផ្សារភ្ជាប់បទដ្ឋាន ការងាររដ្ឋបាល បច្ចេកទេស នីតិវិធី និងហិរញ្ញវត្ថុ ជាពិសេសការបណ្តុះបណ្តាលធនធានមនុស្ស ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងខិតខំពង្រឹងពង្រីកភាពសុខដុមផ្ទៃក្នុង បង្កើតសេវាថ្មីៗ ការកសាងគោលនយោបាយនានា ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិ និងបំពេញការងារសំខាន់ៗមួយចំនួនទៀតដូចខាងក្រោម ៖

## I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានប្រជុំពិភាក្សាការងារជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន បានជួបប្រជុំពិភាក្សាជាមួយឯកឧត្តម លោកជំទាវ ជាប្រធានគណៈកម្មការ និងជួបពិភាក្សាការងារជាមួយភ្ញៀវជាតិ អន្តរជាតិ(ជប៉ុន Conrad, នាយកប្រតិបត្តិPIC ) ទទួលសៀវភៅពីស្ថានទូតរុស្ស៊ី ចូលរួមក្នុងជំនួបសាវនាការវាងឯកឧត្តម **ទេព ង៉ន** និងឯកឧត្តមអគ្គាធិការងនៃរដ្ឋាភិបាលវៀតណាម មហាសន្និបាតលើកទី១២៩ របស់សហភាពអន្តរសភា (IPU) នៅប្រទេសស្វីស ចូលរួមប្រជុំពិភាក្សាការងារផ្សេងៗ ព្រមទាំងបានពិនិត្យសម្រេចលើឯកសារផ្សេងៗចំនួន២៤០ច្បាប់ ។

### ១.សេវាទូទៅទទួលមុខងារតំណាង៖

-បានរៀបចំវេទិកាថ្នាក់ស្រុករបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ស្តីពីការយល់ដឹង និងចាត់តាំងអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព គោលនយោបាយ វិមជ្ឈការ វិសហមជ្ឈការ នៅខេត្តរតនគិរី ។

-រៀបចំបែបបទ និងអមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ចុះទៅតាមបណ្តាខេត្ត រាជធានីទូទាំងប្រទេស ចំនួន១២០លើក ដើម្បីសំណេះសំណាល សាកសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ ព្យាបាលជំងឺ ពិនិត្យការដ្ឋានសាងសង់



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

សម្រេចសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៥៩លើក ។

-ទទួលពាក្យបណ្ដឹង ចំនួន០១ករណី និងបានដោះស្រាយបញ្ចប់ជាស្ថាពរបាន ០១ករណី ព្រមទាំងបានទទួលលិខិតឆ្លើយតបពីក្រសួងយុត្តិធម៌ ចំនួន០១ករណី ។

**២.សេវាទំនាក់ទំនងខាងព័ត៌មាន៖**

-គណៈកម្មការទី១ បានចុះបេសកកម្ម ដើម្បីស្វែងយល់អំពី ការអនុវត្តសិទ្ធិមនុស្ស និងច្បាប់ នៅខេត្តប៉ៃលិន បន្ទាយមានជ័យ និងបាត់ដំបង ។

-គណៈកម្មការទី៥ បានចុះបេសកកម្ម ដើម្បីស្វែងយល់ អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ និងការផ្សព្វផ្សាយព័ត៌មាន នៅខេត្តសៀមរាប និងឧត្តរមានជ័យ ។

-គណៈកម្មការទី៦ ចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ ថ្នាក់ដឹកនាំ និងមន្ត្រីនៃសាលាខេត្ត តុលាការ និងអយ្យការអមតុលាការ នៅខេត្តតាកែវ ។

-គណៈកម្មការទី៨ បានចុះបេសកកម្ម ដើម្បីសិក្សាស្វែងយល់អំពីបញ្ហាសុខភាពសាធារណៈ នៅខេត្តកំពង់ចាម និងខេត្តក្រចេះ

-គណៈកម្មការទី៩ និងសមាជិកព្រឹទ្ធសភា ប្រចាំភូមិភាគទី៧ បានចុះស្រាវជ្រាវ និងប្រមូលព័ត៌មាន ដើម្បីរៀបចំវេទិកា

-សមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ និងទី៤ ចុះសិក្សាស្រាវជ្រាវព័ត៌មាន ដើម្បីត្រៀមរៀបចំវេទិកាស្ដីពីព្រឹទ្ធសភា និងការលើកកម្ពស់ការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងយេនឌ័រ នៅខេត្តកំពង់ចាម និងបន្ទាយមានជ័យ

-សមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ បានចុះសួរសុខទុក្ខ និងចែកអំណោយដល់ប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ នៅខេត្តក្រចេះ ស្ទឹងត្រែង និងរតនគិរី ។

**៣.ការងារអន្តរជាតិ៖**

រៀបចំបែបបទជូនសមាជិកព្រឹទ្ធសភាចូលរួម ៖

-សន្និសីទស្ដីពី"គោលនយោបាយគ្រឿងស្រវឹងសាកលលោក នៅសាធារណរដ្ឋកូរ៉េ

-ទស្សនកិច្ចសិក្សាដកបទពិសោធន៍ការងារ នៅរដ្ឋសភាឡាវ

-មហាសន្និបាត IPU នៅប្រទេសស្វីស

-ទស្សនកិច្ចសិក្សារបស់គណៈប្រតិភូព្រឹទ្ធសភានៅបារាំង និងស្វីស

រៀបចំបែបបទជូនមន្ត្រី អ.ព.ស ចំនួន១៧រូបទៅ ទស្សនកិច្ចសិក្សាលើជំនាញបច្ចេកវិទ្យាព័ត៌មានវិទ្យា និងបច្ចេកទេសគ្រប់គ្រងប្រព័ន្ធ Studio នៅប្រទេសកូរ៉េ, ០១រូបទៅចូលរួមកិច្ចប្រជុំស្តីពីការគ្រប់គ្រងកម្មវិធីបង្រៀនភាសាចិន នៅប្រទេសចិន និង០១រូបចូលរួមសិក្ខាសាលា នៅប្រទេសម៉ាឡេស៊ី ។

-ទំនាក់ទំនងជាមួយដៃគូអន្តរជាតិនានា (India, Brunei, Philippine ឥណ្ឌូនេស៊ី ម៉ាឡេស៊ី វៀតណាម ថៃ រុស្ស៊ី អាល្លឺម៉ង់ អូស្ត្រាលី ស្ថានកុងស៊ុលបែលហ្សិក ស្ថានកុងស៊ុលន័រវែស ) ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

**៣.ទំនាក់ទំនងសាធារណៈ**

-ទំនាក់ទំនងជាមួយស្ថានីយ៍ទូរទស្សន៍ជាតិ ទូរទស្សន៍អាស៊ីអាគ្នេយ៍ ដើម្បីផ្សព្វផ្សាយសមិទ្ធផលនានារបស់ព្រឹទ្ធសភា និងសាកលវិទ្យាល័យ CUS, CMTC, CDC, AEU, ECCC, CWF, NIDA, Hong kong Center ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា។

-បានទទួលមន្ត្រីរាជការ សិស្ស និស្សិត សាធារណៈជន ចូលអានសៀវភៅ ចំនួន២២៦នាក់ ។

**៤.ការអភិវឌ្ឍន៍ធនធានមនុស្ស៖**

-មន្ត្រីចំនួន២៦រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី អ្នកដឹកនាំតាមបែបព្រះពុទ្ធសាសនា ។

-មន្ត្រីចំនួន៤៧នាក់ទទួលអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ នៅតាមសាកលវិទ្យាល័យក្នុងប្រទេស ។

+ **ការបណ្តុះបណ្តាលធនធានមនុស្សក្រៅប្រទេស**

- មន្ត្រីចំនួន០២រូបចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយនៅសហគមន៍មូលដ្ឋាន នៅប្រទេសម៉ាឡេស៊ី, ០១រូបចូលរួមវគ្គ បណ្តុះបណ្តាលស្តីពីវិធីសាស្ត្រក្នុងការលើកកម្ពស់ការសិក្សាភាសាចិន និងវប្បធម៌នៅកម្ពុជា នៅប្រទេសចិន និង០២រូបចូលរួមវគ្គបណ្តុះបណ្តាល រយៈពេលខ្លីស្តីពីការគ្រប់គ្រងសេវាសាធារណៈ នៅប្រទេសស៊ុយអ៊ែត , មន្ត្រី០២រូបចូលរួមសិក្ខាសាលាស្តីពីការគ្រប់គ្រងព័ត៌មានសំរាប់អ្នកប្រឹក្សានយោបាយ និងស្រាវជ្រាវ នៅប្រទេសឥណ្ឌូណេស៊ី ។

-អាហារូបករណ៍ ថ្នាក់បណ្ឌិត និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ចំនួន១២នាក់ នៅប្រទេសចិន និងវៀតណាម ។

**៥.ការអភិវឌ្ឍន៍ស្ថាប័ន៖**

-បន្តទំនាក់ទំនងជាមួយអ្នកបច្ចេកទេសចិន និងទីប្រឹក្សាពាណិជ្ជកម្មចិនក្នុងការសាងសង់អគារ

០៣ខ្នង០៣ជាន់ ការបំពាក់ជណ្តើរយន្ត និងការជម្រុញគម្រោងជំនួយសុំបន្ថែម (សាងសង់អគារបន្ថែម ១ខ្នងទៀត, ប្រព័ន្ធលូទឹក, ផ្លូវថ្នល់, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, ការសាងសង់សាលប្រជុំ ព្រឹទ្ធសភាថ្មី)។

-ការសិក្សាលក្ខណៈបច្ចេកទេសសាងសង់អគារថ្មីរបស់អ្នកបច្ចេកទេសចិន និងការត្រៀមបំពេញកាតព្វកិច្ចសាងសង់របស់ភាគីព្រឹទ្ធសភា ។

**៦. ការងារផ្ទៃក្នុង សន្តិសុខធនធាន មធ្យោបាយ ទីកន្លែង៖**

-ចុះបេសកកម្មចំនួន០៩លើក ទៅខេត្តកណ្តាល ព្រៃវែង ស្វាយរៀង បាត់ដំបង និងខេត្តរតនគិរី ដើម្បីប្រមូលព័ត៌មានត្រៀមរៀបចំវេទិកា ចូលរួមសិក្ខាសាលា និងរៀបចំវេទិកា ។

-ចុះបេសសកម្មអមដំណើរគណៈប្រតិភូព្រឹទ្ធសភាចំនួន០៨លើក ទៅ ខេត្តកំពង់ចាម តាកែវ ប៉ៃលិន បន្ទាយមានជ័យ បាត់ដំបង ក្រចេះ ស្ទឹងត្រែង ខេត្តរតនគិរី និងពោធិ៍សាត់ ដើម្បីប្រមូលព័ត៌មានត្រៀមរៀបចំវេទិកា ពិនិត្យស្ថានភាពគ្រោះទឹកជំនន់ ជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាឃុំ-ខេត្ត-តុលាការ បញ្ហាសុខភាពសាធារណៈ ការអនុវត្តច្បាប់ និងសិទ្ធិមនុស្ស។

-អង្គភាពបេឡាសោធននិវត្តន៍ សោធនបាត់បង់សម្បទាវិជ្ជាជីវៈ និងគណៈកម្មការត្រួតពិនិត្យរៀបចំបោះឆ្នោតជ្រើសរើសតំណាងមន្ត្រីរាជការសម្រាប់បន្តអាណត្តិក្រោយ

-បានរៀបចំទិវាមនុស្សចាស់ សម្រាប់អតីតមន្ត្រីចូលនិវត្ត និងមន្ត្រីជិតចូលនិវត្តនៃអគ្គលេខាធិការដ្ឋាន

-បានដឹកនាំកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ PIC

-បានធ្វើសេចក្តីព្រាងផែនការប្រតិបត្តិប្រចាំ ឆ្នាំ២០១៤ និងផែនការយុទ្ធសាស្រ្តសម្រាប់ ឆ្នាំ២០១២-២០១៨ របស់ក្រុមសមាជិកព្រឹទ្ធសភា ។

-អង្គភាពសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា បានចាត់កងកម្លាំងការពារសន្តិសុខ សណ្តាប់ធ្នាប់ ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន០៨លើក ។

-ថតចម្លងឯកសារ ចំនួន៧៨សំណើ ចងក្រងឯកសារជាសៀវភៅ ចំនួន៨០ក្បាល ដោះស្រាយសំណើថវិកាចំនួន២០០សំណើ និងសម្ភារ ចំនួន៣៤សំណើ ព្រមទាំងផ្តល់សេវាដឹកជញ្ជូនចំនួន៨៩លើក ។

-ប្រគល់ព្រីភ្លើង ចំនួន០១គ្រឿង បិទលេខកូដទូរទស្សន៍,Ipad ចំនួន០៨គ្រឿង និងប្រមូលកៅអី ,Monitor, Keyboard, Printer ចាស់ៗ ចំនួន០៧គ្រឿង ។ បញ្ចូលហ្គាស ជួសជុល ម៉ាស៊ីនត្រជាក់ ទូរស័ព្ទ ទូទឹកកក បន្ទប់ទឹក ទ្វារអាលុយមីញ៉ូម ទ្វារបន្ទប់ទឹក ខឿនថ្នល់ របងសំណាញ់ និងរបងស័ង្កសី ប្តូរអំពូល ព្រី កុងតាក់ ចំនួន១០១គ្រឿង។

-ជួសជុលកុំព្យូទ័រ ត្រួតពិនិត្យ បញ្ចូលកម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធីខ្មែរ Unicode, Office ចុះតាមដាន Internet និង Network សរុបចំនួន ៨០គ្រឿង និងបាន Upload ព័ត៌មាន និងឯកសារផ្សេងៗ ចំនួន៤៧ប្រធានបទ ។

**II.ទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០១៣**

១-ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី៤ (អាចមានលទ្ធភាពប្រជុំវិសាមញ្ញព្រឹទ្ធសភា)

២-ការត្រៀមរបាយការណ៍ចន្លោះសម័យប្រជុំលើកទី៣ និងលើកទី៤(អាទិត្យទី១ ខែវិច្ឆិកា)

៣-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំ ជាមួយគណៈប្រតិភូជាតិអន្តរជាតិ និងអង្គទូតនានា ។

៤-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការ និងក្រសួង ស្ថាប័ន នានា និងការចុះបេសកកម្មតាមបណ្តាខេត្តៗ

៥-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស។

-ការបញ្ជូនគណៈប្រតិភូព្រឹទ្ធសភាទៅបារាំង និងស្វីស ( ខែវិច្ឆិកា )

-ការត្រៀមទទួលគណៈប្រតិភូព្រឹទ្ធសភាបារាំង និងថៃមកធ្វើទស្សនកិច្ចនៅកម្ពុជា(ខែវិច្ឆិកា)

-ទស្សនកិច្ចសិក្សានៅប្រទេសថៃ

-ការត្រៀមពិធីបំពាក់គ្រឿងឥស្សរិយយសជាន់ខ្ពស់របស់ប្រទេសជាមិត្តជូនសម្តេចប្រធានព្រឹទ្ធសភា (វិច្ឆិកា)។

-សហប្រតិបត្តិការជាមួយវិទ្យាស្ថានធនាគារពិភពលោក ដើម្បីត្រៀមរៀបចំកិច្ចប្រជុំនាខែធ្នូ ឆ្នាំ២០១៣ នៅភ្នំពេញ ។

-ការត្រៀមរៀបចំជូនគណប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា ទស្សនកិច្ចនៅចិន។

-ការត្រៀមដំណើរបេសកកម្មរបស់PIC ទៅបារាំង និងស៊ុយអែតក្នុងខែធ្នូ។

៦-ការរៀបចំវេទិកាសាធារណៈរបស់ក្រុមសមាជិកព្រឹទ្ធសភាតាមភូមិភាគ រួមទាំងវេទិកាក្រុមសមាជិកាព្រឹទ្ធសភា ។

៧-ត្រៀមទទួល និងសម្ពោធអគារ៣ខ្នង ៣ជាន់ ជំនួយរបស់រដ្ឋាភិបាល ចិន ។

៨-ការត្រៀមរៀបចំបំពាក់ការប៊ីនភ្លើង ជណ្តើរយន្ត ប្រព័ន្ធអគ្គិសនី លូទឹក សួនច្បារ នៅក្នុងបរិវេណការដ្ឋាន៣ខ្នង និងក្នុងបរិវេណព្រឹទ្ធសភា។

៩-ការរៀបចំដេញថ្លៃគម្រោងលទ្ធកម្មជំហានចុងក្រោយ ។

១០-បន្តរៀបចំលម្អិតគម្រោងថវិកាឆ្នាំ២០១៤ក្រោយពីបានការពារគម្រោងថវិកាឆ្នាំ២០១៤

ជាស្ពានជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កសាងគោលការណ៍អនុវត្តថវិកា ឆ្នាំ២០១៤ ។

**១១**-ជម្រុញការបើកវគ្គសិក្សាជំនាញ ភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មាន និងយកចិត្តទុកដាក់ដល់ការពង្រឹងវិន័យ ប្រតិបត្តិការតាមគោលការណ៍3E (ប្រសិទ្ធភាព ប្រសិទ្ធផល សន្សំសំចៃ) និងការស្វែងរកអាហារូបករណ៍ក្នុង និងក្រៅប្រទេស ( រូបមន្ត០៤៖ **ចង់ ចូល ចេះ ចប់** )

**១២**-បន្តពិចារណាអំពីការរៀបចំ និងដាក់ឲ្យអនុវត្តអង្គភាពថវិកា សម្រាប់៤អង្គភាពជាជំហានដំបូង

**១៣**-ការគិតគូរដល់ដំណើរការប្រព័ន្ធការងារ មធ្យោបាយ និងធនធានសម្រាប់គ្រប់អង្គភាព ព្រមទាំងជីវភាព សុខុមាលភាព មន្ត្រីរាជការ តាមរបប៣៖របបសន្តិសុខសង្គម របបធានារ៉ាប់រងសុខភាព និងរបបសោធននិវត្តន៍ ។

-សហការជាមួយរដ្ឋសភា/ក្រុមប្រឹក្សាធម្មនុញ្ញ សិក្សាអំពីបញ្ហា តម្លើងបៀវត្សក្របខ័ណ្ឌ " គ " និង " ឃ " ។

**១៤**-ពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិរបស់គ្រប់អង្គភាពអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំឆ្នាំ២០១៣ និងការរៀបចំផែនការប្រតិបត្តិឆ្នាំ២០១៤ ព្រមទាំងបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្ររបស់អគ្គលេខាធិការដ្ឋាន និងអគ្គនាយកដ្ឋានទាំង៣ ។

**១៥**-បន្តតាមដានគម្រោងសាងសង់អគារថ្មីជាមួយ ទីប្រឹក្សាពាណិជ្ជកម្មចិន

**១៦**-បញ្ចប់ការកែសម្រួលរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងចងក្រងនីតិវិធីអនុវត្តបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាដោយធានាភាពគ្រប់ជ្រុងជ្រោយ Comprehensiveness, សុពលភាព Validity, ភាពត្រឹមត្រូវ Accuracy

**១៧**-បន្តពង្រឹងដំណើរការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ។

**១៨**-ការរៀបចំបំពាក់គ្រឿងឥស្សរិយយសដល់មន្ត្រី និងគិតគូរការរៀបចំសមាសភាពគ្រប់គ្រងអង្គភាពបេឡាសោធននិវត្តន៍ និងគណៈកម្មការត្រួត ពិនិត្យបេឡាសោធននិវត្តន៍ ព្រមទាំងគណៈកម្មការនារីរបស់អគ្គលេខាធិការដ្ឋាន ។

**១៩**-បន្តសិក្សា និងរៀបចំចងក្រងប្រវត្តិព្រឹទ្ធសភា និងប្រវត្តិអគារក្រហម អគារ៤ខ្នង ជាជំនួយរបស់ចិន និងអគារ២ខ្នង ជាជំនួយរបស់ជប៉ុន ។

**២០**-បន្តអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមកិច្ចសហប្រតិបត្តិការជាមួយវៀតណាម ចិន កូរ៉េ ឥណ្ឌា និងជប៉ុន ( វៀតណាមនឹងជួយរៀបចំប្រព័ន្ធ Intranet ) ។

**២១**-បន្តយុទ្ធនាការស្វែងរកការគាំទ្រ និងជំនួយពីប្រភពក្នុង/ក្រៅប្រទេស សំរាប់ព្រឹទ្ធសភា

តាមរយៈវិទ្យាស្ថានសភាកម្ពុជា។

-កិច្ចសហប្រតិបត្តិការជាមួយ KOICA, JICA, CAMSERV, VN, CHINA, BRUNEI, វិទ្យាស្ថានធនាគារពិភពលោក,វិទ្យាស្ថានសភាកម្ពុជា

២២-រៀបចំចងក្រងប្រវត្តិព្រឹទ្ធសភា និងប្រវត្តិអគារក្រហម អគារ៤ខ្នង ជាជំនួយរបស់ចិន និងអគារ២ខ្នង ជាជំនួយរបស់ជប៉ុន។

២៣-ត្រៀមបូកសរុបប្រចាំឆ្នាំ សារពើភ័ណ្ឌទ្រព្យសម្បត្តិ សារពើភ័ណ្ឌ ធនធានមនុស្ស/ជំនាញ សារពើភ័ណ្ឌឯកសារ ។

២៤-ត្រៀមការបោះពុម្ពដំណាច់ឆ្នាំ ។

III.**សេចក្តីសន្និដ្ឋាន**

ក្នុងខែនេះ ជាខែដែលមានការឈប់សំរាកច្រើនថ្ងៃ ជារយៈពេលវិស្សមកាលរបស់ព្រឹទ្ធសភា ដែលថ្នាក់ដឹកនាំសមាជិក-សមាជិកាព្រឹទ្ធសភា បានយកចិត្តទុកដាក់ខ្ពស់លើការងារមូលដ្ឋាន ពិសេសការជួយសង្គ្រោះប្រជាពលរដ្ឋដែលរងគ្រោះដោយទឹកជំនន់ ។ ទន្ទឹមនឹងនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានស្វែងរកដៃគូក្នុង និងក្រៅប្រទេស ដើម្បីពង្រឹងពង្រីកការបណ្តុះបណ្តាលធនធានមនុស្សឲ្យកាន់តែមានសមត្ថភាពខ្ពស់ និងបំពេញមុខងាររបស់ខ្លួនយ៉ាងសកម្ម ដោយធានានូវសេវាគ្រប់ប្រភេទ ទទួលបានលទ្ធផលល្អ ពង្រឹងការគោរពវិន័យ ពង្រីកនូវវប្បធម៌ សាមគ្គីភាព និងសហប្របត្តិការការងារឲ្យបានកាន់តែល្អប្រសើរ ។

កិត្យានុភាពរបស់ស្ថាប័នត្រូវបានលើកកម្ពស់ក្នុងក្របខ័ណ្ឌ AIPA , IPU , និង APF ។

ភ្នំពេញ,ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៣

**អគ្គលេខាធិការ**

**អ៊ុំ_សារិទ្ធ**